ACCESS 2
Sustainable quality services for all

Australian Aid

ព្រឹត្តិបត្រព័ត៌មានខេត្ត

ACCESS 2 ក្នុងខេត្តកំពង់ស្ពឺ

កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព សមធម៌ - ដំណាក់កាលទី២

ព័ត៌មានសង្ខេបអំពីខេត្តកំពង់ស្ពឺ

១៩%
នៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល [1]

៦,២%
នៃចំនួនប្រជាជនមានពិការភាពក្នុងទម្រង់ណាមួយ[2]

៨
ដៃគូ ACCESS 2 កំពុងធ្វើការនៅក្នុងខេត្តនេះ

[1] ស្ត្រីដែលធ្លាប់មានដៃគូ អាយុពី១៥ដល់៤៩ឆ្នាំ ធ្លាប់បានទទួលរងអំពើហិង្សាផ្នែកផ្លូវកាយ ផ្លូវភេទ ឬផ្លូវអារម្មណ៍នៅដំណាក់កាលណាមួយក្នុងជីវិតរបស់ពួកគេ។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២។

[2] តាមរបាយការណ៍បានឱ្យដឹងថា ក្រុមប្រជាជនដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅ មានការលំបាកក្នុងកម្រិតណាមួយ (មានការលំបាកខ្លះ មានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានសោះ)។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤ និងឆ្នាំ២០២១-២០២២។

តើ ACCESS 2 ធ្វើអ្វីខ្លះក្នុងខេត្តកំពង់ស្ពឺ



កម្មវិធី ACCESS 2 កំពុងអនុវត្តសកម្មភាពនៅខេត្តកំពង់ស្ពឺ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាដែលមានការសម្របសម្រួល និងបរិយាបន្នសម្រាប់អ្នកនៅរស់រានពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងជនមានពិការភាព។ ការគាំទ្ររបស់ប្រទេសអូស្ត្រាលីបានរួមចំណែកពង្រឹងការងារទាំងបីផ្នែករបស់កម្មវិធីនៅក្នុងខេត្តនេះ រួមមាន មជ្ឈមណ្ឌលស្តារលទ្ធ-ភាពពលកម្មកាយសម្បទាខេត្ត(PRC) ការឆ្លើយតបចំពោះ GBV និងបរិយាបន្នពិការភាព។

គណៈកម្មាធិការសម្របសម្រួលថ្នាក់ខេត្ត បានលើកទឹកចិត្តអាជ្ញាធរថ្នាក់ក្រោមជាតិ និងដៃគូអនុវត្តឱ្យធ្វើការរួមគ្នា ក្នុងការរៀបចំផែនការ ចែករំលែកទិន្នន័យ និងដោះស្រាយបញ្ហា។ រីឯក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត និងក្រុមការងារឆ្លើយតបGBV ជំរុញការអនុវត្តនៅថ្នាក់មូលដ្ឋាន។ ដៃគូអនុវត្តនានា បានគាំទ្រដល់ការបង្កើតបន្ទប់ប្រឹក្សាយោបល់ផ្នែកGBV ប្រព័ន្ធបញ្ជូនបន្ត និងយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងទៅដល់សហគមន៍នៅស្រុកនានាក្នុងខេត្ត។



សេវានានាកំពុងបន្តពង្រឹងគុណភាព រួមមាន សេវាព្យាបាលការប្រាស្រ័យទាក់ទង និងភាសា (ST) ត្រូវបានបង្កើតឡើងនៅមន្ទីរពេទ្យបង្អែកខេត្ត។ កន្លែងផ្តល់សេវាចម្រុះ(OSSU) សម្រាប់អ្នកនៅរស់រានមានជីវិតពី GBV កំពុងដំណើរការ ហើយអង្គការតំណាងជនមានពិការភាព កំពុងតែជួយសម្រួលដល់លទ្ធភាពទទួលបានសេវាសាធារណៈ ដែលអាចប្រើប្រាស់បានកាន់ តែច្រើនសម្រាប់ជនមានពិការភាព។

ការងារអាទិភាពដែលកំពុងអនុវត្តនៅខេត្តកំពង់ស្ពឺ

- អំពើហិង្សាទាក់ទងនឹងយេនឌ័រ
- បរិយាបន្នពិការភាព
- ការស្តារលទ្ធភាពពលកម្ម

លទ្ធផលសម្រេចបាននៅខេត្តកំពស់ស្ពឺ គិតត្រឹមខែមិថុនា ឆ្នាំ២០២៦

៦.៦១៨ នាក់
បានទទួលសេវា PRC ចន្លោះពីខែកក្កដា ឆ្នាំ២០២៤ ដល់ខែមិថុនា ឆ្នាំ២០២៥

២៣.៤២០ នាក់
ជាជនមានពិការភាព ត្រូវបានកំណត់អត្តសញ្ញាណ ក្នុងនោះ ៣.៧០៣នាក់ បានទទួលអត្ថប្រយោជន៍ពីកញ្ចប់គ្រួសារ

៥៨៥ នាក់
ជាអ្នកនៅរស់រានពី GBV ទទួលបានការគាំទ្ររួមទាំងការប្រឹក្សាយោបល់ និងតំណាងផ្នែកច្បាប់ដោយឥតគិតកម្រៃ

តើយើងធ្វើការជាមួយអ្នកណាខ្លះក្នុងខេត្តកំពង់ស្ពឺ

ដៃគូជារដ្ឋាលបានខេត្ត

- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត
- មន្ទីរកិច្ចការនារីខេត្ត
- មន្ទីរសុខាភិបាលខេត្ត
- ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត
- ក្រុមការងារឆ្លើយតប GBV
- មូលនិធិជនពិការ
- គណៈកម្មាធិការឃុំ សង្កាត់ ទទួលបន្ទុកការងារស្ត្រី និងកុមារ (គ.ក.ន.ក)

ដៃគូអនុវត្ត និងសង្គមស៊ីវិល

- អង្គការជនពិការកម្ពុជា
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិកម្ពុជា (CWCC)
- គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC)
- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)
- អង្គការ OIC Cambodia
- អង្គការ PAfID
- អង្គការ UNICEF, UNFPA និង UN Women
- អង្គការតំណាងជនមានពិការភាព (OPDs)
- វេទិកាស្ត្រីមានពិការភាព

សកម្មភាពចម្បងៗក្នុងខេត្តកំពង់ស្ពឺ

ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

- គាំទ្រការបង្កើត OSSU សម្រាប់អ្នកនៅរស់រានពី GBV នៅមន្ទីរពេទ្យបង្អែកខេត្ត
- គាំទ្រក្រុមការងារឆ្លើយតប GBV ចំនួន៨ (ថ្នាក់ខេត្ត១ និងថ្នាក់ស្រុក៧) និងបណ្តុះបណ្តាលសមាជិកបានចំនួន៦៩៨នាក់ អំពីការផ្តល់ប្រឹក្សា ការបញ្ជូន និងស្តង់ដានៃការគាំទ្រតាមផ្លូវច្បាប់
- បង្កើតបន្ទប់ប្រឹក្សាយោបល់សម្រាប់ករណី GBV ដែលរក្សាការសម្ងាត់ នៅតាមឃុំចំនួន៩ ក្នុងស្រុកចំនួន៤

ផ្នែកបរិយាបន្នពិការភាព

- គាំទ្រការកំណត់អត្តសញ្ញាណកម្មជនមានពិការភាព (មនុស្សចំនួន ២៣.៤២០នាក់ ត្រូវបានកំណត់អត្តសញ្ញាណ ហើយបណ្ណសម្គាល់ជនមានពិការភាពចំនួន ១៩,៣២៧ បណ្ណ ត្រូវបានចេញជូន)
- ពង្រឹងក្រុមប្រឹក្សាសកម្មភាពជនមានពិការថ្នាក់ខេត្ត ដែលមានសមាជិកចំនួន៥៩រូប រួមទាំងOPDs ចំនួន១០
- គាំទ្រការវាយតម្លៃជាសុកវត្ថុដែលធ្វើឡើងដោយOPDs ដោយជំរុញឱ្យឃុំផ្តល់ថវិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធជាសុកវត្ថុ

ផ្នែកការស្តារលទ្ធភាពពលកម្ម

- គាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ស្ពឺ
- ដាក់ឱ្យអនុវត្តសេវា ST នៅមន្ទីរពេទ្យបង្អែកខេត្ត តាមរយៈបន្ទប់គាំទ្រការប្រាស្រ័យទាក់ទង និងភាសា
- ការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលសហគមន៍ចំនួន១២នាក់ និងបុគ្គលិកមន្ទីរពេទ្យចំនួន៤នាក់ អំពីជំនាញ ST



“ កម្មវិធី ACCESS 2 បានបំលែងការផ្តល់សេវាសម្រាប់ជនមានពិការភាព និងអ្នកនៅរស់រានពី GBV ដោយពង្រឹងការសម្របសម្រួល ភាពជាម្ចាស់ក្នុងចំណោមស្ថាប័នរដ្ឋាភិបាលនានា និងដៃគូក្នុងមូលដ្ឋាន ព្រមទាំងលំហូរបញ្ជូនដែលមានលក្ខណៈសមាហរណកម្ម។ ជាលទ្ធផល ជនងាយរងគ្រោះអាចទទួលបានសេវាចាំបាច់កាន់តែងាយស្រួល និងទទួលបានការគាំទ្រទាន់ពេលវេលា ប្រកបដោយការគោរព និងផ្តោតលើតម្រូវការរបស់អ្នកនៅរស់រានមានជីវិតជាស្នូល ដោយរក្សានូវសិទ្ធិ សេចក្តីថ្លៃថ្នូរ និងភាពធន់របស់ពួកគេ។ ”

លោកជំទាវ គា សុភូ អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ស្ពឺ

អគារ ANINA ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

info@access2cambodia.org www.access2cambodia.org

ACCESS 2 ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយ Abt Global